# កិច្ចការនៅក្នុងថ្ងៃចុងក្រោយសម្រាប់មរណជន



អែលឌើរ ចន អេ វីឌសូ ( ១៨៧២–១៩៥២ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀននូវទំនាក់ទំនងខាងក្រោមនេះអំពីបេសកកម្មដែលត្រូវបានតែងតាំងពីមុនកំណើតលោកិយមកដើម្បីជួយសង្គ្រោះដល់បុត្រា និងបុត្រីរបស់ព្រះ ៖

« នៅក្នុងស្ថានភាពពីមុនកំណើតលោកិយរបស់យើង នៅក្នុងជំនាន់នៃការប្រឹក្សាដ៏អស្ចារ្យ យើងបានធ្វើកិច្ចព្រមព្រៀងមួយជាមួយនឹងព្រះដ៏មានព្រះចេស្ដា ។ ព្រះអម្ចាស់បានដាក់ស្នើនូវផែនការមួយ ដែលត្រូវបានផ្ដើមឡើងដោយទ្រង់ ។ យើងបានយល់ព្រម ។ ដោយសារផែនការនេះមានបំណងជួយដល់មនុស្សទាំងអស់ នោះយើងក្លាយទៅជាភាគីចំពោះសេចក្ដីសង្គ្រោះដល់បុគ្គលគ្រប់រូបនៅក្នុងផែនការនោះ ។ យើងបានយល់ព្រម គឺនៅពេលនោះ និងនៅទីនោះ ដែលវាមិនគ្រាន់តែជាព្រះសង្គ្រោះសម្រាប់ខ្លួនយើងនោះទេ ប៉ុន្តែ. . .ជាព្រះសង្គ្រោះសម្រាប់គ្រួសារមនុស្សទាំងមូលផងដែរ ។ យើងបានចូលរួមជាដៃគូមួយរបស់ព្រះអម្ចាស់ ។ ពេលនោះ ដំណោះស្រាយចំពោះផែនការនេះមិនមែនគ្រាន់តែជាកិច្ចការរបស់ព្រះវរបិតាតែម្នាក់ និងជាកិច្ចការរបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាកិច្ចការរបស់យើងផងដែរ ។ យើងរាល់គ្នាដ៏តូចជាងគេបំផុត បន្ទាបខ្លួនជាងគេបំផុត ស្ថិតនៅក្នុងការចូលរួមជាដៃគូជាមួយនឹងព្រះដ៏មានព្រះចេស្ដាដើម្បីសម្រេចឲ្យបាននូវព្រះបំណងនៃផែនការដ៏អស់កល្បជានិច្ចនៃសេចក្ដីសង្គ្រោះ ( « The Worth of Souls » *Utah Genealogical and Historical Magazine,* ខែ តុលា ឆ្នាំ ១៩៣៤ ទំព័រ ១៨៩ ) » ( នៅក្នុង *Doctrine and Covenants and Church History: Gospel Doctrine Teacher's Manual* [ ឆ្នាំ ១៩៩៩ ], ទំព័រ ១៧៣ ) ។



អែលឌើរ រីឆាដ ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានលើកទឹកចិត្តដល់យុវជននៃសាសនាចក្រឲ្យធ្វើកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ដូនតារបស់ពួកគេផ្ទាល់ ៖

« កិច្ចការអ្វីដែលអ្នកធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ គឺជាពេលដែលចំណាយបានល្អ ប៉ុន្តែការទទួលពិធីបរិសុទ្ធ ជំនួសជីដូនជីតាផ្ទាល់ខ្លួនរបស់អ្នក នឹងធ្វើឲ្យពេលវេលាក្នុងព្រះវិហារបរិសុទ្ធកាន់តែពិសិដ្ឋ ហើយថែមទាំងទទួលបាន ពរជ័យកាន់តែអស្ចារ្យទៀតផង ។ . . .

« តើមនុស្សវ័យក្មេងដូចជាអ្នក ចង់បានវិធីដ៏ប្រាកដមួយ ដើម្បីលុបបំបាត់ឥទ្ធិពលរបស់មារសត្រូវមានក្នុងជីវិតរបស់អ្នកឬទេ? សូមអ្នកចុះប្រឡូកក្នុងការស្រាវជ្រាវរកជីដូនជីតាអ្នក រៀបចំឈ្មោះរបស់ពួកគាត់សម្រាប់ពិធីបរិសុទ្ធជំនួសដ៏ពិសិដ្ឋដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ រួចហើយទៅព្រះវិហារបរិសុទ្ធ ដើម្បីឈរជាអ្នកទទួលពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធជំនួសពួកគាត់ ។ . . . ខ្ញុំគិតមិនឃើញនូវកិច្ចការពារដ៏កាន់តែធំសម្បើមពីឥទ្ធិពលរបស់មារសត្រូវក្នុងជីវិតរបស់អ្នកនោះឡើយ » ( « The Joy of Redeeming the Dead » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៩៣–៩៤ ) ។



អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានធ្វើការអញ្ជើញដូចខាងក្រោមនេះ និងបានសន្យា ៖

« ខ្ញុំសូមអញ្ជើញយុវវ័យនៃសាសនាចក្រឲ្យរៀន និងទទួលបានបទពិសោធន៍នៃវិញ្ញាណនៃអេលីយ៉ា ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យសិក្សា ស្វែងរកជីដូនជីតារបស់អ្នក ហើយត្រៀមខ្លួនរបស់អ្នកដើម្បី ធ្វើបុណ្យជ្រមុជទឹកជំនួសនៅក្នុងព្រះដំណាក់នៃព្រះអម្ចាស់ សម្រាប់ញាតិសន្តានដែលស្លាប់*របស់អ្នក* ( សូមមើល គ និង ស ១២៤:២៨–៣៦ ) ។ ហើយខ្ញុំសូមជម្រុញឲ្យអ្នកជួយអ្នកដទៃឲ្យរកមើលពង្សប្រវត្តិរបស់ពួកគេ ។

« នៅពេលអ្នកឆ្លើយតបដោយសេចក្ដីជំនឿតាមការអញ្ជើញនេះ ដួងចិត្តរបស់អ្នកនឹងបែរទៅរកឪពុក ។ សេចក្ដីសន្យាទាំងឡាយដែលបានធ្វើឡើងជាមួយនឹងអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប នឹងត្រូវបានបណ្ដុះនៅក្នុងដួងចិត្តរបស់អ្នក ។ ពរជ័យអយ្យកោរបស់អ្នក ជាមួយនឹងសេចក្ដីប្រកាសរបស់វាអំពីខ្សែស្រឡាយ នឹងភ្ជាប់អ្នកទៅនឹងអយ្យកោទាំងនេះ និងមានន័យកាន់តែខ្លាំងដល់អ្នក ។ សេចក្ដីស្រឡាញ់របស់អ្នក និងការដឹងគុណចំពោះដូនតារបស់អ្នកនឹងកើនឡើង ។ ទីបន្ទាល់របស់អ្នក និងការប្រែចិត្តទៅរកព្រះអង្គសង្គ្រោះនឹងមានកាន់តែជ្រាលជ្រៅ និងមាំមួន ។ ហើយខ្ញុំសូមសន្យាដល់អ្នកថា អ្នកនឹងត្រូវបានការពារប្រឆាំងនឹងឥទ្ធិពលដ៏ខ្លាំងនៃឧបសគ្គនានា ។ នៅពេលអ្នកប្រឡូក ហើយស្រឡាញ់កិច្ចការដ៏បរិសុទ្ធនេះ នោះអ្នកនឹងមានសុវត្ថិភាពនៅក្នុងយុវវ័យ និងពេញមួយជីវិតរបស់អ្នក » ( « The Hearts of the Children Shall Turn » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៦–២៧ ) ។

© 2015 ដោយ Intellectual Reserve Inc. រក្សាសិទ្ធិគ្រប់យ៉ាង

សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ | ថ្នាក់សិក្ខាសាលា និងវិទ្យាស្ថានសាសនា